ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៣៣ ❀ ៥៥

ក្រសួងមហាផ្ទៃ

លេខ: ២៥៧៤ /ប្រក

ក្រសួងការងារ

និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# ប្រកាសអន្តរក្រសួង

## ស្តីពី

## នីតិវិធី និងបែបបទ នៃការផ្តល់លិខិតឆ្លងដែនធម្មតាជូនពលករ-ពលការិនីខ្មែរ ទៅធ្វើការដោយស្របច្បាប់នៅបរទេស

៣៣ ❀ ៥៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ        រដ្ឋមន្ត្រី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ៥២ អនក្រ.បក ចុះថ្ងៃទី ០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ១៩០ អនក្រ.បក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងលើការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេសតាមរយៈទីភ្នាក់ងារជ្រើសរើសឯកជន
- បានឃើញអនុក្រឹត្យលេខ២០៥ អនក្រ.បក ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការផ្តល់លិខិតឆ្លងដែនធម្មតាជូនពលករ ពលការិនី និងសិស្សនិស្សិតខ្មែរ
- យោងតាមសំណូមពរចាំបាច់នៃការងារ។

## សម្រេច

**ប្រការ ១._**

ប្រកាសនេះមានគោលបំណងកំណត់អំពីនីតិវិធី និងបែបបទ នៃការផ្តល់លិខិតឆ្លងដែនធម្មតាជូនពលករ ពលការិនីខ្មែរ ដែលទៅធ្វើការដោយស្របច្បាប់នៅបរទេស សំដៅបង្កភាពងាយស្រួល ដល់ពលករ ពលការិនីខ្មែរ ទទួលបានលិខិតឆ្លងដែនធម្មតាដោយអាករជាបន្ទុករបស់រដ្ឋ ។

**ប្រការ ២.-**

ពលករ ពលការិនីខ្មែរ ដែលទៅធ្វើការដោយស្របច្បាប់នៅបរទេស សំដៅដល់៖

-ពលករ ពលការិនីដែលមានកិច្ចសន្យាការងារតាមរយៈក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

-ពលករ ពលការិនីដែលបានចុះកិច្ចសន្យាការងារតាមរយៈទីភ្នាក់ងារជ្រើសរើសឯកជន។

-ពលករ ពលការិនីដែលបានចុះកិច្ចសន្យាការងារជាមួយនិយោជក នៃប្រទេសដែលពលករពលការិនីត្រូវទៅធ្វើការ។

កិច្ចសន្យាការងារ ត្រូវមានការបញ្ជាក់ទទួលស្គាល់ដោយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្របតាមអនុក្រឹត្យលេខ ១៩០ អនក្រ.បក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងលើការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេសតាមរយៈទីភ្នាក់ងារជ្រើសរើសឯកជន និងអនុក្រឹត្យលេខ ២០៥អនក្រ.បក ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការផ្តល់លិខិតឆ្លងដែនធម្មតាជូនពលករ ពលការិនី និងសិស្សនិស្សិតខ្មែរ ។

**ប្រការ ៣.-**

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈមានភារកិច្ច៖

- ចេញឯកសារបញ្ជាក់ទទួលស្គាល់ និងប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេសជូនពលករពលការិនីខ្មែរ និង
- រៀបចំសំណុំបែបបទស្នើសុំលិខិតឆ្លងដែនធម្មតាជូនពលករ ពលការិនីខ្មែរដែលត្រូវទៅធ្វើការស្របច្បាប់នៅបរទេសដោយអាករជាបន្ទុករបស់រដ្ឋ បន្ទាប់ពីទទួលបានសំណុំឯកសារពីទីភ្នាក់ងារជ្រើសរើសឯកជន ឬពីពលករ ពលការិនី រយៈពេលយ៉ាងយូរ ២ថ្ងៃនៃថ្ងៃធ្វើការ បញ្ជូនទៅអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ឬសាខាផ្តល់លិខិតឆ្លងដែនប្រចាំខេត្ត របស់ក្រសួងមហាផ្ទៃ។

**ប្រការ ៤.-**

ក្រសួងមហាផ្ទៃ មានភារកិច្ច៖

- បំពេញបែបបទ ផ្តល់លិខិតឆ្លងដែនធម្មតា ជូនពលករ ពលការិនីខ្មែរដែលត្រូវទៅធ្វើការស្របច្បាប់នៅបរទេសដោយអាករជាបន្ទុករបស់រដ្ឋ តាមសំណុំឯកសារស្នើសុំរបស់អគ្គនាយកដ្ឋានការងារ ឬមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ នៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។
- ផ្តល់លិខិតឆ្លងដែនធម្មតាជូនពលករ ពលការិនីខ្មែរ ដែលត្រូវទៅធ្វើការស្របច្បាប់នៅបរទេសក្នុងរយៈពេលយ៉ាងយូរ ១៥ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីពលករ ពលការិនីបានបំពេញបែបបទត្រឹមត្រូវគ្រប់គ្រាន់នៅនាយកដ្ឋានលិខិតឆ្លងដែន ឬសាខាផ្តល់លិខិតឆ្លងដែនប្រចាំខេត្ត។

**ប្រការ ៥.-**

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ធ្វើប្រតិភូកម្មអំណាចជូន អគ្គនាយកដ្ឋានការងារ រៀបចំសំណុំបែបបទស្នើសុំផ្តល់លិខិតឆ្លងដែនធម្មតាជូនពលករ ពលការិនីខ្មែរដែលត្រូវទៅធ្វើការស្របច្បាប់នៅបរទេសដោយអាករជាបន្ទុករបស់រដ្ឋ បញ្ជូនទៅអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម និងធ្វើប្រតិភូកម្មអំណាចជូនមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីចេញឯកសារបញ្ជាក់ និងបំពេញបែបបទស្នើសុំលិខិតឆ្លងដែនធម្មតាជូនពលករ ពលការិនីខ្មែរ ដែលត្រូវទៅធ្វើការស្របច្បាប់នៅបរទេសដោយអាករជាបន្ទុករបស់រដ្ឋ ដើម្បីបញ្ជូនទៅសាខាផ្តល់លិខិតឆ្លងដែនប្រចាំខេត្ត និងត្រូវរាយការណ៍ប្រចាំសប្តាហ៍ជូនអភិបាលនៃគណៈអភិបាលខេត្ត ។

ក្រសួងមហាផ្ទៃ ធ្វើប្រតិភូកម្មអំណាចជូន អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ពិនិត្យសម្រេចលើសំណុំបែបបទស្នើសុំផ្តល់លិខិតឆ្លងដែនធម្មតាជូនពលករ ពលការិនីខ្មែរដែលត្រូវទៅធ្វើការស្របច្បាប់នៅបរទេសដោយអាករជាបន្ទុករបស់រដ្ឋ ដែលបញ្ជូនមកពីអគ្គនាយកដ្ឋានការងារ និងធ្វើប្រតិភូកម្មអំណាចជូនសាខាផ្តល់លិខិតឆ្លងដែនប្រចាំខេត្ត សម្រាប់បំពេញបែបបទផ្តល់លិខិតឆ្លងដែនធម្មតាជូនពលករ ពលការិនីខ្មែរ ដែលត្រូវទៅធ្វើការស្របច្បាប់នៅបរទេសដោយអាករជាបន្ទុករបស់រដ្ឋ ផ្អែកលើសំណុំឯកសារស្នើសុំរបស់មន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងត្រូវរាយការណ៍ប្រចាំសប្តាហ៍ជូនអភិបាលនៃគណៈអភិបាលខេត្ត ។

**ប្រការ ៦.-**

អភិបាលនៃគណៈអភិបាលខេត្ត មានភារកិច្ចៈ

-ជួយបង្កលក្ខណៈងាយស្រួលដល់ការរៀបចំច្រកចេញ-ចូលតែមួយ សម្រាប់មន្ត្រីមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមន្ត្រីសាខាផ្តល់លិខិតឆ្លងដែនប្រចាំខេត្ត ធ្វើការបំពេញបែបបទផ្តល់លិខិតឆ្លងដែនធម្មតាជូនពលករ ពលការិនីខ្មែរដែលត្រូវទៅធ្វើការស្របច្បាប់នៅបរទេសដោយអាករជាបន្ទុករបស់រដ្ឋ ។

-តាមដានត្រួតពិនិត្យការអនុវត្តការងាររបស់មន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងសាខាផ្តល់លិខិតឆ្លងដែនប្រចាំខេត្ត ឲ្យបានត្រឹមត្រូវតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ស្តីពីការផ្តល់លិខិតឆ្លងដែនធម្មតាជូនពលករ ពលការិនីខ្មែរដែលត្រូវទៅធ្វើការស្របច្បាប់នៅបរទេសដោយអាករជាបន្ទុករបស់រដ្ឋ ។

**ប្រការ ៧.-**

ពលករ ពលការិនីខ្មែរដែលមានការបញ្ជាក់ទទួលស្គាល់ពីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬ មន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈទៅធ្វើការស្របច្បាប់នៅបរទេសដោយអាករលិខិតឆ្លងដែនជាបន្ទុករបស់រដ្ឋត្រូវៈ

- ទៅបំពេញសំណុំបែបបទសុំផ្តល់លិខិតឆ្លងដែនធម្មតាដោយផ្ទាល់នៅនាយកដ្ឋានលិខិតឆ្លងដែន ឬនៅសាខាផ្តល់លិខិតឆ្លងដែនប្រចាំខេត្ត ដូចជាៈ បំពេញពាក្យស្នើសុំលិខិតឆ្លងដែន ថតរូប ផ្តិតខ្លៅម្រាមដៃ ចុះហត្ថលេខា វាស់កម្ពស់ និងយកកិនភាគីស្លាកស្នាម
- ភ្ជាប់មកជាមួយនូវឯកសារច្បាប់ដើម ឬច្បាប់ថតចម្លងត្រឹមត្រូវតាមច្បាប់ដើមដូចខាងក្រោមៈ
  - អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬសំបុត្រកំណើត និង
  - សៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារ

**ប្រការ ៨.–**

ក្រសួងមហាផ្ទៃ និងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បង្កើតច្រកចេញ-ចូលតែមួយ ដើម្បីជួយសម្រួលដល់ការបំពេញបែបបទផ្តល់លិខិតឆ្លងដែនជូនពលករ ពលការិនីខ្មែរដែលបាននឹងកំពុងធ្វើការក្នុងព្រះរាជាណាចក្រថៃហើយមិនទាន់មានឯកសារគ្រប់គ្រាន់តាមច្បាប់ ចំនួន ៤កន្លែង នៅច្រកប៉ោយប៉ែតខេត្តបន្ទាយមានជ័យ ច្រកព្រំខេត្តប៉ៃលិន ច្រកចាំយាមខេត្តកោះកុង និងច្រកអូរស្មាច់ខេត្តឧត្តរមានជ័យ ។

បែបបទដែលត្រូវអនុវត្តសម្រាប់ការផ្តល់លិខិតឆ្លងដែននេះ ត្រូវបានកំណត់ដូចតទៅ៖

-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬសំបុត្រកំណើត និង សៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារ

-ប័ណ្ណអនុញ្ញាតិឲ្យធ្វើការងារបណ្តោះអាសន្ន ដែលចេញដោយមជ្ឈមណ្ឌលច្រកចេញ-ចូលតែមួយរបស់ថៃ

-បញ្ជីឈ្មោះពលករ ពលការិនីខ្មែរ រៀបចំដោយមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយផ្អែកលើប័ណ្ណអនុញ្ញាតិឲ្យធ្វើការងារបណ្តោះអាសន្ន ដែលចេញដោយមជ្ឈមណ្ឌលច្រកចេញ-ចូលតែមួយរបស់ថៃ

-ផ្តល់បង្កាន់ដៃជូនពលករ ពលការិនី សម្រាប់ការទទួលយកលិខិតឆ្លងដែន។

**ប្រការ ៩.–**

ត្រូវទទួលទណ្ឌកម្មរដ្ឋបាល ឬ/និង ទទួលទោសតាមច្បាប់ជាធរមានចំពោះជនណាដែល៖

- ផ្តល់ព័ត៌មានខុសពីការពិតក្នុងសំណុំបែបបទសុំផ្តល់លិខិតឆ្លងដែនធម្មតាសម្រាប់ពលករ ពលការិនីខ្មែរដែលអាករជាបន្ទុករបស់រដ្ឋ
- កាន់កាប់ ឬប្រើប្រាស់លិខិតឆ្លងដែនធម្មតាសម្រាប់ពលករ ពលការិនីខ្មែរដោយអាករជាបន្ទុករបស់រដ្ឋ ដែលខ្លួនមិនមែនជាពលករ ពលការិនីខ្មែរត្រូវទៅធ្វើការស្របច្បាប់នៅបរទេស
- ក្លែង កោស លុប ឬ សរសេរត្រួតលើលិខិតឆ្លងដែនធម្មតា
- មានចេតនាជួយសម្រួលសំណុំបែបបទ ឬសម្រេចផ្តល់លិខិតឆ្លងដែនធម្មតាដោយអាករជាបន្ទុករបស់រដ្ឋដល់ជនណាដែលមិនមែនជាពលករ ពលការិនីខ្មែរត្រូវទៅធ្វើការស្របច្បាប់នៅបរទេស ។

**ប្រការ ១០.–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ១១.–**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន អគ្គនាយក នៃអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋាន

និងប្រធានអង្គភាពពាក់ព័ន្ធនានា នៃក្រសួងមហាផ្ទៃ អគ្គនាយក នៃអគ្គនាយកដ្ឋានការងារ អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ ប្រធានអង្គភាពពាក់ព័ន្ធនានា នៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ អភិបាល នៃគណៈអភិបាលខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ២០១៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

ស ខេង

**រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ**

អ៊ិត សំហេង

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី-ខេត្ត
- ដូចប្រការ ១១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ